ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# ទស្សនាទាន

## ស្ដីពី

## សិក្ខាសាលាស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

មិថុនា ២០២៦

## មាតិកា


១. សេចក្ដីផ្ដើម ........................................................ ១

២. គោលបំណង និងលទ្ធផលរំពឹងទុក ........................................ ៣

៣. ប្រធានបទក្នុងសិក្ខាសាលា ............................................. ៣

៤. សមាសភាពក្នុងសិក្ខាសាលា ............................................. ៣

៥. កាលបរិច្ឆេទ ទីកន្លែង និងភាសា ....................................... ៤

ឧបសម្ព័ន្ធទី១ សេចក្ដីព្រាងមាតិកា "ក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា" ..................... ៥

ឧបសម្ព័ន្ធទី២ នីតិកម្មវិទ្យាក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ .................................. ១៤

ឧបសម្ព័ន្ធទី៣ សេចក្ដីព្រាងរបៀបវារៈ ................................................ ១៥

## ១. សេចក្តីផ្តើម

ស្របតាមមុំទី៤ នៃស្ទួលយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.) ត្រូវបានបង្កើតឡើង ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីជាយន្តការ ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធីនយោបាយរបស់ រាជរដ្ឋាភិបាល ក្នុងគោលបំណងពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃច្បាប់។ ដើម្បីជាទិសដៅការងារសម្រាប់ គ.ក.ច **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្ត "**ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល**" កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ជាមួយនឹងចក្ខុវិស័យ "**គ.ក.ច. ជានិម្មាបនករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជានិងគុណតម្លៃសាកល**"។

ការដឹកនាំ និងសម្របសម្រួលចងក្រង និងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គឺជាយុទ្ធសាស្ត្រមួយនៅក្នុងផែនការកម្មវិធីការងាររយៈពេល ២០ឆ្នាំ របស់ គ.ក.ច ដែលមានការរៀបចំក្រមនីយកម្មគតិយុត្តតាមវិស័យជាកម្មវិធីគាំទ្រ។ ក្នុងន័យនេះ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** បានផ្តល់អនុសាស៍ដឹកនាំដល់អគ្គលេខាធិការដ្ឋាន គ.ក.ច. ក្នុងការសិក្សាលម្អិតអំពីការរៀបចំទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា។

នៅក្នុងក្របខ័ណ្ឌការងាររបស់ គ.ក.ច. កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ កិច្ចប្រជុំស្តីពីការរៀបចំក្រមពាណិជ្ជកម្មត្រូវបានប្រព្រឹត្តឡើងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំមកពីក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សាអ្នកច្បាប់ អ្នកជំនាញការច្បាប់ តំណាងក្រសួង ស្ថាប័ន អង្គភាព និយ័តករ មេធាវី និងតួអង្គពាក់ព័ន្ធផ្សេងទៀត។ កិច្ចប្រជុំនេះបានរៀបចំឡើងក្នុងគោលបំណងពិនិត្យ និងពិភាក្សាលើការកំណត់វិសាលភាព និងវិធីសាស្ត្រនៃការតាក់តែងក្រម។ ជាលទ្ធផលអង្គប្រជុំបានសម្រេចដកចេញនូវ ទំនាក់ទំនងរវាងពាណិជ្ជករនិងរដ្ឋ (B2G) និងរក្សាទុកទំនាក់ទំនងរវាងពាណិជ្ជករនិងពាណិជ្ជករ (B2B)

និងទំនាក់ទំនងរវាងពាណិជ្ជករនិងអ្នកប្រើប្រាស់ចុងក្រោយ(B2C) រួមជាមួយវិធីសាស្ត្រនៃការតាក់តែងក្រម សម្រាប់ជាកម្មវត្ថុនៃកិច្ចពិភាក្សានិងពិគ្រោះយោបល់ប្រមូលធាតុចូលនាពេលខាងមុខ។

នៅក្នុងក្របខ័ណ្ឌការងារ របស់អគ្គលេខាធិការដ្ឋាន គ.ក.ច **ឯកឧត្តម លី ច័ន្ទតុលា អនុប្រធាន និងជាអគ្គលេខាធិការ គ.ក.ច.** អមដោយមន្ត្រី និងអ្នកជំនាញការច្បាប់នៃអគ្គលេខាធិការដ្ឋាន គ.ក.ច. ចំនួន ៧រូប បានធ្វើទស្សនៈកិច្ចសិក្សា នៅទីក្រុងប៉ារីស ប្រទេសបារាំង ថ្ងៃទី១៨ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ ទៅកាន់ (១) គណៈកម្មការជាន់ខ្ពស់ក្រមនីយកម្មបារាំង ដើម្បីស្វែងយល់អំពីប្រវត្តិនៃការបង្កើត ដំណើរការរៀបចំ ការប្រព្រឹត្តទៅ តួនាទី របស់គណៈកម្មការជាន់ខ្ពស់ក្រមនីយកម្មបារាំង និងការចែករំលែកបទពិសោធការងារជាដើម។ (២)មហាវិទ្យាល័យច្បាប់នៃសាលកលវិទ្យាល័យ Paris I Panthéon de la Sorbonne ដើម្បីផ្លាស់ប្តូរបទពិសោធនិងការរួមចំណែកលើការរៀបចំក្រមពាណិជ្ជកម្ម (៣)អ្នកជំនាញក្រមនីយកម្មបារាំង ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធលើកិច្ចការក្រមនីយកម្ម ជាពិសេសគឺការពិភាក្សាលើក្រមពាណិជ្ជកម្ម និងក្រមនីយកម្មឌីជីថល។ (៤) សភាពាណិជ្ជកម្មនៃទីក្រុងប៉ារីសសាធារណរដ្ឋបារាំង ដើម្បផ្លាស់ប្តូរបទពិសោធលើកិច្ចការក្រមនីយកម្ម ជាពិសេសវិធាននៃការដោះស្រាយវិវាទពាណិជ្ជកម្មរបស់សភាពាណិជ្ជកម្មអន្តរជាតិ( International Chamber of Commerce) ក្នុងការរៀបចំបទដ្ឋានធុរកិច្ចនិងពាណិជ្ជកម្ម ព្រមទាំងការដោះស្រាយវិវាទពាណិជ្ជកម្ម និង(៥)សមាគមន៍ Henri Capitan ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធលើការរៀបចំ ការកំណត់ដែនកំណត់ មាតិកា ខ្លឹមសារ ដែលជាវិធានសារធាតុ នៅក្នុងសេចក្តីព្រាងក្រមសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

ជារួម តាមស្មារតីនៃកិច្ចប្រជុំ និងលទ្ធផលនៃទស្សនកិច្ចសិក្សាខាងលើនេះ គ.ក.ច. បានចង្អុលបង្ហាញឱ្យអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងគណៈកម្មាធិការផ្តល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម (**គ.ផ.គ.ព.**) សហការគ្នាក្នុងការរៀបចំទស្សនាទានស្តីពីការរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ដើម្បីប្រមូលធាតុចូល ស្វែងយល់ពីគោលគំនិត និងបញ្ហាជាក់ស្តែងទាំងក្នុងវិស័យឯកជន វិស័យសាធារណៈ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងការរៀបចំក្រមពាណិជ្ជកម្មរបស់កម្ពុជា។ ក្នុងន័យនេះ ដើម្បីជាមូលដ្ឋាននៃការរៀបចំ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានរៀបចំនូវសេចក្តីព្រាងមាតិកាដូចបានកំណត់ក្នុង **ឧបសម្ព័ន្ធទី១** និងស្រាវជ្រាវពីវិធីសាស្ត្រនៃការតាក់តែងក្រមដូចបានកំណត់ក្នុង **ឧបសម្ព័ន្ធទី២**។

## ២. គោលបំណង និងលទ្ធផលរំពឹងទុក

### ❖ គោលបំណង

ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា គឺជាគម្រោងដ៏ស្មុគស្មាញមួយដែលទាមទារឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅអំពីវិធីសាស្ត្រក្នុងនោះមានដូចជា ការចងក្រង, ការប្រមូលផ្តុំ និងរៀបចំក្រម (Compilation, Consolidationn, or Codification) យន្តការរៀបចំ (ប្រភពច្បាប់ វិធាននីតិវិធី វិធានស្ថាប័ន) និង យន្តការគាំទ្រ (ធនធានមនុស្ស និងហិរញ្ញវត្ថុ) គួបផ្សំនឹងយុទ្ធសាស្ត្រទំនាក់ទំនងអន្តរក្រសួង ស្ថាប័ន ភាគីឯកជន និងដៃគូអភិវឌ្ឍន៍។ ក្នុងន័យនេះ សិក្ខាសាលាស្តីពី "**ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា**" នឹងត្រូវរៀបចំឡើងដោយមានការចូលរួមពីសំណាក់តួអង្គពាក់ព័ន្ធទាំងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីពិនិត្យ និងពិភាក្សាលើ៖

(១) ទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

(២) ការកំណត់នូវវិធីសាស្ត្រតាក់តែងក្រមមួយដែលឆ្លើយតបនឹងតម្រូវការជាក់ស្តែង និង

(៣) ការកំណត់វិសាលភាពនៃទំនាក់ទំនងពាណិជ្ជកម្មដែលនឹងត្រូវដាក់បញ្ចូលក្នុងក្រមនេះ (ក្នុងការកំណត់មាតិកាក្រមនេះ)។

### ❖ លទ្ធផលរំពឹងទុក

នៅក្នុងដំណាក់កាលប្រមូលផ្តុំគំនិតនេះ ធាតុចូលដែលប្រមូលបានពីសិក្ខាសាលានឹងត្រូវយកមកសិក្សា បំពេញបន្ថែម ក្នុងសេចក្តីព្រាងទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ដើម្បីដាក់ជូន គ.ក.ច. ពិនិត្យនិងសម្រេច។ ទស្សនាទាននេះ ដើរតួនាទីជាមគ្គទេសក៍បង្ហាញផ្លូវក្នុងដំណាក់កាលនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា។

## ៣. ប្រធានបទក្នុងសិក្ខាសាលា

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកខាងលើ ប្រធានបទសម្រាប់ធ្វើបទបង្ហាញ និងកិច្ចពិភាក្សាត្រូវបានកំណត់ ដូចខាងក្រោម៖

១. ទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

២. វិធីសាស្ត្ររៀបចំក្រមពាណិជ្ជកម្ម ជាឧត្តមានុវត្តន៍អន្តរជាតិ

៣. វិសាលភាពនៃទំនាក់ទំនងពាណិជ្ជកម្មដែលនឹងត្រូវដាក់បញ្ចូលក្នុងក្រម

៤. ផលវិបាក សំណើ ដំណោះស្រាយ និងទិសដៅការងារបន្ត។

## ៤. សមាសភាពក្នុងសិក្ខាសាលា

សិក្ខាសាលាស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ត្រូវបានផ្តួចផ្តើមដោយទីស្តីការគណៈរដ្ឋមន្ត្រី និងមានការចូលរួមសហការរៀបចំដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់(**គ.ក.ច.**) និង

គណៈកម្មាធិការផ្ដល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម(**គ.ផ.គ.ព.**) និងមានអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ជាសេនាធិការបច្ចេកទេសក្នុងការដឹកនាំរៀបចំ។ សិក្ខាសាលានេះ មានការចូលរួមពី **គ.ក.ច.** តំណាងគណៈកម្មាធិការដឹកនាំការកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងក្រុមការងារជំនាញនៃទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សាអ្នកច្បាប់ ថ្នាក់ដឹកនាំទទួលបន្ទុកគោលនយោបាយ ផែនការ និងថ្នាក់ដឹកនាំទទួលបន្ទុកកិច្ចការងារនីតិកម្ម និងកែទម្រង់ច្បាប់ ពីគ្រប់ក្រសួងស្ថាប័ន ចៅក្រមនិងព្រះរាជអាជ្ញា តំណាងអគ្គនាយកដ្ឋានពន្ធដារ តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ សភាពាណិជ្ជកម្មជាតិនិងអន្តរជាតិ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ស្ថានទូត ក្រុមហ៊ុនមេធាវី សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា សមាគមឧកញ៉ាកម្ពុជាសមាគមនិយោជក សម្ព័ន្ធអ្នកច្បាប់នៅកម្ពុជា សមាគមសាលាត្រាជូ ដៃគូអភិវឌ្ឍន៍ តំណាងសាកលវិទ្យាល័យនីតិសាស្ត្រ និងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធចំនួន ៣៦៤រូប។

**៥. កាលបរិច្ឆេទ ទីកន្លែង និងភាសា**

ថ្នាក់ដឹកនាំ និងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ក.ច. បានធ្វើការសិក្សាលើពេលវេលា ទីតាំង និងភាសា សម្រាប់ដំណើរការសិក្ខាសាលាដូចខាងក្រោម៖

| | | |
|---|---|---|
| **កាលបរិច្ឆេទ** | ៖ | ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦ |
| **ពេលវេលា** | ៖ | ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១៨:០០ នាទីល្ងាច |
| **ទីតាំង** | ៖ | សណ្ឋាគារសុខាភ្នំពេញ |
| **ភាសា** | ៖ | ខ្មែរ អង់គ្លេស និងបារាំង |
| របៀបវារៈ | ៖ | **ឧបសម្ព័ន្ធទី៣** |

## ឧបសម្ព័ន្ធទី១ សេចក្តីព្រាងមាតិកា "ក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា"

**គន្ថីទី១ បទប្បញ្ញត្តិទូទៅ**

**មាតិកាគោល បទប្បញ្ញត្តិទូទៅ**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (គោលបំណង វិសាលភាព សទ្ទានុក្រម)

ជំពូកទី២ គោលការណ៍ទូទៅ

ជំពូកទី៣ សមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននិងការរៀបចំសេចក្តីព្រាងគោលនយោបាយពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម

ផ្នែកទី១. ការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម

ផ្នែកទី២. ការរៀបចំសេចក្តីព្រាងគោលនយោបាយពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម

**គន្ថីទី២ វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម[1] និងសហគ្រាសពាណិជ្ជកម្ម**

**មាតិកាទី១ វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ** (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

**ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ**

**ជំពូកទី៣ ការចុះបញ្ជី**

ផ្នែកទី១ បញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុន ការកាន់កាប់ និងកម្មវត្ថុនៃបញ្ជី

ផ្នែកទី២ ពាណិជ្ជករដែលមានគ្រឹះស្ថានដើមនៅកម្ពុជា

ផ្នែកទី៣ ក្រុមហ៊ុនដែលមានទីស្នាក់ការដើមនៅកម្ពុជា

ផ្នែកទី៤ ក្រុមហ៊ុនបរទេសដែលមានតែសាខា ឬទីភ្នាក់ងារនៅកម្ពុជា

ផ្នែកទី៥ អំពីបញ្ជីពាណិជ្ជកម្ម រូបភាពនិងសមាសភាព

ផ្នែកទី៦ ការដាក់ពាក្យស្នើសុំសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន

ផ្នែកទី៧ ការចុះបញ្ជីកែប្រែ

ផ្នែកទី៨ នីតិវិធីនៃការចុះបញ្ជីឡើងវិញក្នុងបញ្ជីពាណិជ្ជកម្ម

**ជំពូកទី៤ កាតព្វកិច្ចគណនេយ្យ និងតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ**

**ជំពូកទី៥ លេខាធិការក្រុមហ៊ុន**

**ជំពូកទី៦ ការទទួលពាក្យបណ្តឹងនៅក្នុងសមត្ថកិច្ចក្រសួងពាណិជ្ជកម្ម**

**មាតិកាទី២ សហគ្រាសពាណិជ្ជកម្ម[2]**

[1] ដកស្រង់មកពីច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងប្រកាសស្តីពីការធ្វើសាមញ្ញកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម

[2] ដកស្រង់មកពីច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)**

**ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ**

**ជំពូកទី៣ សហគ្រាសឯកបុគ្គល**

ផ្នែកទី១ ការបង្កើតសហគ្រាសឯកបុគ្គល

**ជំពូកទី៤ ក្រុមហ៊ុនសហកម្មសិទ្ធិ**

ផ្នែកទី១ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ផ្នែកទី២ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

**ជំពូកទី៥ ក្រុមហ៊ុនមូលធន**

ផ្នែកទី១ ការបង្កើតក្រុមហ៊ុនមូលធន

ផ្នែកទី២ សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន

ផ្នែកទី៣ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និងកំណត់ហេតុ

ផ្នែកទី៤ អភិបាល និងអ្នកគ្រប់គ្រងក្រុមហ៊ុន

ផ្នែកទី៥ ភាគហ៊ុន និងភាគលាភ

ផ្នែកទី៦ មូលបត្រ ការចុះបញ្ជី និងការផ្ទេរ

ផ្នែកទី៧ អ្នកទទួលរក្សាទ្រព្យសម្បត្តិ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

ផ្នែកទី៨ ម្ចាស់ហ៊ុន

ផ្នែកទី៩ របាយការណ៍ហិរញ្ញវត្ថុ (កាតព្វកិច្ចផ្ទៃក្នុង)

ផ្នែកទី១០ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

ផ្នែកទី១១ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា[3]

**ជំពូកទី៦ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស**

ផ្នែកទី១ ការិយាល័យតំណាងពាណិជ្ជកម្ម

ផ្នែកទី២ សាខាក្រុមហ៊ុនពាណិជ្ជកម្ម

ផ្នែកទី៣ បុត្រសម្ព័ន្ធ

## គន្ថីទី៣ ម៉ាកនិងពាណិជ្ជនាម

### មាតិកាទី១ ម៉ាកនិងពាណិជ្ជនាម

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)**

**ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ**

[3] សម្រាប់នីតិវិធីផ្ទៃក្នុងរបស់ក្រុមហ៊ុន មាត្រា២៤១ ដល់ ២៥០ (ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម)។

ជំពូកទី៣ ការចុះបញ្ជី និងសិទ្ធិដែលកើតឡើងពីការចុះបញ្ជី

ជំពូកទី៤ មោឃភាព និងការលុបម៉ាកចេញពីបញ្ជី

ជំពូកទី៥ ម៉ាកសមូហភាព

ជំពូកទី៦ ការផ្តល់អាជ្ញាបណ្ណចំពោះម៉ាក

ជំពូកទី៧ ពាណិជ្ជនាម

**មាតិកាទី២ ការប្រកួតប្រជែងមិនស្មោះត្រង់**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ជំពូកទី៤ ការរំលោភ និងវិធានការដោះស្រាយ

ជំពូកទី៥ វិធានការបណ្តោះអាសន្ន

ជំពូកទី៦ វិធានការតាមមាត់ច្រកព្រំដែន

ជំពូកទី៧ ការប្តូរម្ចាស់កម្មសិទ្ធិ

ជំពូកទី៨ ការកាន់បញ្ជីម៉ាក

ជំពូកទី៩ ភ្នាក់ងារ

ជំពូកទី១០ ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ និងការបកស្រាយ

**គន្ថីទី៤ ប្រតិបត្តិការពាណិជ្ជកម្ម**

**មាតិកាទី១ ទំនាក់ទំនងនៃការតំណាង**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣ ការតំណាង[4]

ជំពូកទី៤ អាណត្តិ[5]

**មាតិកាទី២ កិច្ចសន្យាពាណិជ្ជកម្ម**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣[6] ការលក់-ទិញ[7]

---

[4] Agency law - Civil Code art. 364 (Book 4, Ch. 2, Pt 4, Pg. 133)

[5] Agency law - Civil Code art. 637 (Book 5, Ch. 7, Pg. 230)

[6] B2B Sales

[7] Sales Law - Civil Code art. 515 (Book 5, Ch. 1, Pg. 186)

ផ្នែកទី១ លក្ខណៈនៃការលក់ និងការបង្កើតកិច្ចសន្យាលក់ទិញ
ផ្នែកទី២ ភាគី និងកម្មវត្ថុកិច្ចសន្យាលក់ទិញ
ផ្នែកទី៣ ការផ្ទេរកម្មសិទ្ធិ
ផ្នែកទី៤ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកលក់
ផ្នែកទី៥ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទិញ
ផ្នែកទី៦ ការរំលាយកិច្ចសន្យា
**ជំពូកទី៤ ភតិសន្យាហិរញ្ញវត្ថុ**
ផ្នែកទី១ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ
ផ្នែកទី២ សិទ្ធិ និងកាតព្វកិច្ចរបស់ភតិបតី
ផ្នែកទី៣ សិទ្ធិ និងកាតព្វកិច្ចរបស់ភតិកៈ
**ជំពូកទី៥ កិច្ចសន្យា និងហត្ថលេខាអេឡិចត្រូនិក**
**ជំពូកទី៦ មូលនិធិពាណិជ្ជកម្ម**[8]
**មាតិកាទី៣ ឧបករណ៍អាចជួញដូរបាន**
**ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)**
**ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ**
**ជំពូកទី៣ មូលប្បទានបត្រ**
ផ្នែកទី១ ការចេញ និងទម្រង់នៃមូលប្បទានបត្រ
ផ្នែកទី២ បិដ្ឋិលេខមូលប្បទានបត្រ
ផ្នែកទី៣ រូបិយបដិភោគមូលប្បទានបត្រ
ផ្នែកទី៤ ការបង្ហាញមូលប្បទានបត្រ និងការទូទាត់សងប្រាក់
ផ្នែកទី៥ មូលប្បទានបត្រធូតបន្ទាត់ និងមូលប្បទានបត្រទូទាត់សងចូលក្នុងគណនី
ផ្នែកទី៦ ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់ (រយៈពេល)
ផ្នែកទី៧ បេឡាវិនិច្ឆ័យមូលប្បទានបត្រ
ផ្នែកទី៨ ការកែប្រែមូលប្បទានបត្រ
**ជំពូកទី៤ រូបិយាណត្តិ**
ផ្នែកទី១ ការចេញផ្សាយ និងទម្រង់រូបិយាណត្តិ
ផ្នែកទី២ បង្អិលេខរូបិយាណត្តិ

[8] សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម

ផ្នែកទី៣ ស្វ័ការរូបិយាណត្តិ

ផ្នែកទី៤ រូបិយបដិភោគរូបិយាណត្តិ

ផ្នែកទី៥ ឥណប្រតិទានរូបិយាណត្តិ

ផ្នែកទី៦ ការទូទាត់សងប្រាក់

ផ្នែកទី៧ ឧបាស្រ័យចំពោះការមិនធ្វើស្វ័ការ ឬការមិនទូទាត់សងប្រាក់ (រយៈពេល)

ផ្នែកទី៨ ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

ផ្នែកទី៩ ផ្នែកទាំងឡាយនៃបិយាណត្តិមួយច្បាប់ និងច្បាប់ចម្លង

**ជំពូកទី៥ បណ្ណសងតាមបញ្ជា**

ផ្នែកទី១ ការចេញផ្សាយ និងទម្រង់នៃបណ្ណសងតាមបញ្ជា

ផ្នែកទី២ បិដ្ឋិលេខបណ្ណសងតាមបញ្ជា

ផ្នែកទី៣ ការទទួលខុសត្រូវរបស់អ្នកចេញបណ្ណសងតាមបញ្ជា

ផ្នែកទី៤ រូបិយបដិភោគបណ្ណសងតាមបញ្ជា

ផ្នែកទី៥ ឥណប្រតិទានបណ្ណសងតាមបញ្ជា

ផ្នែកទី៦ ការទូទាត់សងប្រាក់

ផ្នែកទី៧ ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់ (រយៈពេល)

ផ្នែកទី៨ ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

ផ្នែកទី៩ ច្បាប់ចម្លង

ផ្នែកទី១០ ការកែលើបណ្ណសងតាមបញ្ជា

**មាតិកាទី៤ ប្រតិបត្តិការទូទាត់សងប្រាក់**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)**

**ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ**

**ជំពូកទី៣ ប្រតិបត្តិការទូទាត់សងប្រាក់**

ផ្នែកទី១ កម្មវត្ថុនៃការអនុវត្ត

ផ្នែកទី២ បញ្ជាទូទាត់

ផ្នែកទី៣ អ្នកដំណើរការតិយភាគី

ផ្នែកទី៤ ការបញ្ចប់ការផ្ទេរឥណទាន និងការសងបំណុល

ផ្នែកទី៥ ការបញ្ចប់ការផ្ទេរឥណពន្ធ និងការសងបំណុល

ផ្នែកទី៦ ការទទួលខុសត្រូវ ការខូចខាត និងសំណង

**មាតិកាទី៥ ប្រតិបត្តិការដែលមានកិច្ចធានា**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣ ប្រតិបត្តិការដែលមានកិច្ចធានា

ផ្នែកទី១ សុក្រឹតកម្ម និងអាទិភាព

ផ្នែកទី២ ការតម្កល់លិខិតជូនដំណឹង

ផ្នែកទី៣ ការអនុវត្ត

**គន្ថីទី៥ ការប្រកួតប្រជែង និងកិច្ចការពារអ្នកប្រើប្រាស់**

**មាតិកាទី១ ការប្រកួតប្រជែង**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣ ការព្រមព្រៀងដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

ជំពូកទី៤ សកម្មភាពបំពានដោយជំហរឧត្តមភាពលើទីផ្សារ

ជំពូកទី៥ ការរួមបញ្ចូលគ្នានៃធុរកិច្ច

ជំពូកទី៦ ការលើកលែងចំពោះការព្រមព្រៀងខ្សែដេក ខ្សែឈរ សកម្មភាពបំពានជំហរឧត្តមភាពលើទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ច

ជំពូកទី៧ គោលការណ៍អនុគ្រោះ

**មាតិកាទី២ កិច្ចការពារអ្នកប្រើប្រាស់**[9]

ជំពូកទី១ បទប្បញ្ញត្តិទូទៅ (កំណត់ផ្នែកវិសោធនកម្ម និងនិរាករណ៍)

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ

ជំពូកទី៣ សមាគមអ្នកប្រើប្រាស់

ជំពូកទី៤ អំពើមិនសុចរិតក្នុងធុរកិច្ច

ជំពូកទី៥ ការអនុវត្តមិនសុចរិត

ជំពូកទី៦ ព័ត៌មានសម្រាប់អ្នកប្រើប្រាស់

**គន្ថីទី៦ ស្ថានភាពលំបាកក្នុងពាណិជ្ជកម្ម**

**មាតិកាទី១ ការបង្ការ និងទប់ស្កាត់ការលំបាករបស់សហគ្រាស**

ជំពូកទី១. ការបង្ការ និងទប់ស្កាត់ការលំបាករបស់សហគ្រាស ការតែងតាំងភ្នាក់ងារពិសេស (*Mandat ad hoc*) និងនីតិវិធីផ្សះផ្សា (*Procédure de conciliation*)

[9] B2C Sales

ជំពូកទី២. បទប្បញ្ញត្តិដែលអនុវត្តចំពោះនីតិបុគ្គលឯកជនដែលមិនមែនជាពាណិជ្ជករ ប៉ុន្តែមានសកម្មភាពសេដ្ឋកិច្ច

**មាតិកាទី២. នីតិវិធីការពារ** ( Sauvegarde )

ជំពូកទី១. ការបើកនីតិវិធី

ជំពូកទី២. សហគ្រាសក្នុងអំឡុងពេលសង្កេតការណ៍ (*Période d'observation*)

ជំពូកទី៣. ការរៀបចំរបាយការណ៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន

ជំពូកទី៤. ការកំណត់ទ្រព្យសម្បត្តិរបស់កូនបំណុល

ជំពូកទី៥. ការទូទាត់បំណុលដែលកើតចេញពីកិច្ចសន្យាការងារ

ជំពូកទី៦. ផែនការការពារ (*Plan de sauvegarde*)

ជំពូកទី៧. បទប្បញ្ញត្តិពិសេសនៅពេលគ្មានអ្នកគ្រប់គ្រងតុលាការ (*Administrateur judiciaire*)

ជំពូកទី៨. នីតិវិធីការពារបន្ទាន់ (*Sauvegarde accélérée*)

**មាតិកាទី៣. ការស្តារអាជីវកម្មតាមផ្លូវតុលាការ** ( Redressement judiciaire )

ជំពូកទី១. ការបើក និងដំណើរការនីតិវិធីស្តារអាជីវកម្ម

ជំពូកទី២. ការលុបចោលសកម្មភាពផ្លូវច្បាប់មួយចំនួន

**មាតិកាទី៤. ការរំលាយសហគ្រាសតាមផ្លូវតុលាការ**

( De la liquidation judiciaire et du rétablissement professionnel )

ជំពូកទី១. លក្ខខណ្ឌសម្រាប់ការបើកនីតិវិធីរំលាយសហគ្រាស

ជំពូកទី២. សាលក្រមប្រកាសរំលាយសហគ្រាស

ជំពូកទី៣. ការលក់ និងការបម្លែងទ្រព្យសកម្មជាសាច់ប្រាក់

ជំពូកទី៤. ការទូទាត់បំណុល

ជំពូកទី៥. នីតិវិធីរំលាយសហគ្រាសបែបសាមញ្ញ

**មាតិកាទី៥. ការបិទបញ្ចប់សហគ្រាស**

ជំពូកទី១. ការបិទបញ្ចប់សហគ្រាសទូទៅ

ជំពូកទី២. ការបិទបញ្ចប់សហគ្រាសដែលមានការលំបាក

**គន្ថីទី៧ ការដោះស្រាយវិវាទ**

**មាតិកាទី១ វិវាទពាណិជ្ជកម្ម**[10]

ជំពូកទី១ បទប្បញ្ញត្តិទូទៅ

ជំពូកទី២ សន្ទានកម្មផ្នែកពាណិជ្ជកម្ម

ផ្នែកទី១ សន្ទានកម្មផ្នែកពាណិជ្ជកម្ម

[10] "commerce" scope: Law on Commercial Arbitration Art 2( i ).

ផ្នែកទី២ សមាសភាពនៃវេទិកាសន្ទានកម្ម

ផ្នែកទី៣ ដំណើរការនៃនីតិវិធីសន្ទានកម្ម

ផ្នែកទី៤ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សាជាតិ និងអន្តរជាតិ

**ជំពូកទី៣ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

ផ្នែកទី១ កិច្ចព្រមព្រៀងមជ្ឈត្តកម្ម

ផ្នែកទី២ សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

ផ្នែកទី៣ សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

ផ្នែកទី៤ ដំណើរការនៃនីតិវិធីមជ្ឈត្តការ

ផ្នែកទី៥ ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម និងការបញ្ចប់ដំណើរការមជ្ឈត្តការ

ផ្នែកទី៦  បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

ផ្នែកទី៧  ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យជាតិ និងអន្តរជាតិ

ជំពូកទី៤. តុលាការពាណិជ្ជកម្ម

**មាតិកាទី២ វិវាទអ្នកប្រើប្រាស់**

ជំពូកទី១ បទប្បញ្ញត្តិទូទៅ

ជំពូកទី២ យន្តការនៃការដោះស្រាយវិវាទអ្នកប្រើប្រាស់

ជំពូកទី៣ នីតិវិធីនៃការដោះស្រាយវិវាទអ្នកប្រើប្រាស់

**គន្ថីទី៨ ទោសប្បញ្ញត្តិ**

**មាតិកាទី១ បទប្បញ្ញត្តិទូទៅ**

ជំពូកទោល បទប្បញ្ញត្តិរួម

**មាតិកាទី២ បទល្មើសក្នុងវិស័យពាណិជ្ជកម្ម**

ជំពូកទី១  បទល្មើសពាក់ព័ន្ធនឹងវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម

ជំពូកទី២  បទល្មើសពាក់ព័ន្ធនឹងម៉ាកនិងពាណិជ្ជនាម

ជំពូកទី៣  បទល្មើសពាក់ព័ន្ធនឹងឧបករណ៍អាចជួញដូរបាន

ជំពូកទី៤  បទល្មើសពាក់ព័ន្ធនឹងប្រតិបត្តិការដែលមានកិច្ចធានា

ជំពូកទី៥  បទល្មើសពាក់ព័ន្ធនឹងការប្រកួតប្រជែងមិនស្មោះត្រង់

ជំពូកទី៦  បទល្មើសពាក់ព័ន្ធនឹងការប្រកួតប្រជែងនិងកិច្ចការពារអ្នកប្រើប្រាស់

ជំពូកទី៧  បទល្មើសពាក់ព័ន្ធនឹងក្ស័យធន

**គន្ថីទី៩ អន្តរប្បញ្ញត្តិ**

**គន្ថីទី១០ អវសានប្បញ្ញត្តិ**

## សន្ធានុក្រម
## សេចក្តីពន្យល់ក្រម

## ឧបសម្ព័ន្ធទី២ នីតិកម្មវិទ្យាក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ

បទដ្ឋានគតិយុត្ត ត្រូវបង្កើតឡើងក្នុងករណីចាំបាច់និងសំខាន់បំផុត ដោយត្រូវធានាគតិយុត្តភាពរឹងមាំ (JURIDIQUEMENT SOLIDE) និងការតាក់តែងប្រកបដោយភាពច្បាស់លាស់(CLAIREMENT ECRITE)។ បទដ្ឋានគតិយុត្ត ត្រូវគ្រោងរៀបចំដោយផ្អែកតាមការចាំបាច់ ចំនួន៣ គឺទី១. ការកំណត់ដោយក្របខ័ណ្ឌគតិយុត្តជាធរមាន ទី២. ទិសដៅនៃការកែទម្រង់និងគោលនយោបាយ និងទី៣. ការវិវឌ្ឍសង្គម សេដ្ឋកិច្ច និងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

ការតាក់តែងក្រម គឺជាឧត្តមានុវត្តន៍អន្តរជាតិ ក្នុងការសិក្សានិងកំណត់គោលការណ៍និងវិធីសាស្ត្រគតិយុត្ត រួមមានការប្រមូលផ្តុំ និងចងក្រងលិខិតបទដ្ឋានគតិយុត្ត ផ្អែកតាមចំណាត់ថ្នាក់អត្ថបទប្រកបដោយរចនាសម្ព័ន្ធជាក់លាក់តាមតក្កវិជ្ជាគតិយុត្ត ដើម្បីសម្រេចបានជាកម្រងឯកសារមួយ ដែលមានមាតិការួមតែមួយ។ ការតាក់តែងក្រម មានវិធីសាស្ត្រចំនួនបី ដែលបែងចែកជាកម្រិត គឺកម្រិតស្រាល កម្រិតមធ្យម និងកម្រិតគ្រប់ជ្រុងជ្រោយ ដូចខាងក្រោម៖

- ការចងក្រង (COMPILATION) ឬកម្រិតស្រាល៖ សំដៅដល់ការប្រមូលផ្តុំអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាក់តាមលំដាប់លំដោយ ដែលរៀបចំតាមកម្មវត្ថុគតិយុត្តនិង/ឬកាលប្បវត្តិ និងផ្ទៀងផ្ទាត់ធរមានប្បញ្ញត្តិ ដោយធានាឱ្យបាននូវគោលការណ៍ បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកា។
- ការប្រមូលផ្តុំ (CONSOLIDATION) ឬកម្រិតមធ្យម៖ សំដៅដល់ការប្រមូលចងក្រង និងប្រមូលផ្តុំបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយបង្ហាញនិង/ឬបញ្ចូលនូវបទដ្ឋានគតិយុត្តដែលវិសោធនកម្ម និងបទដ្ឋានគតិយុត្តនិរាករណ៍ ដោយពុំកែប្រែខ្លឹមសារឡើយ និងធានាឱ្យបាននូវគោលការណ៍ពិនិត្យានុកូលភាព ពោលគឺដើម្បីសម្រួលដល់ការស្វែងរកនិងស្វែងយល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។
- ក្រម (CODIFICATION) ឬកម្រិតគ្រប់ជ្រុងជ្រោយ៖ គឺជាការប្រមូល និងចងក្រងនូវបទប្បញ្ញត្តិគតិយុត្តជាធរមាននានា ទាំងកម្រិតច្បាប់ និងកម្រិតអនុវត្តប្រកបដោយរចនាសម្ព័ន្ធជាក់លាក់តាមតក្កវិជ្ជាគតិយុត្តមួយច្បាស់លាស់ និងក្នុងវិស័យជាក់លាក់ ដើម្បីសម្រេចបានឯកសារមួយដែលមានមាតិការួមហៅថា "ក្រម"។

## ឧបសម្ព័ន្ធទី៣ របៀបវារៈ
## សិក្ខាសាលាស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

| ម៉ោង | កម្មវិធី | រយៈពេល |
|---|---|---|
| ០៨:០០ - ០៨:៤៥ | ការអញ្ជើញមកដល់ និងចុះឈ្មោះ | ៤៥ នាទី |
| ០៨:៤៥ - ០៩:០០ | គណៈអធិបតីអញ្ជើញមកដល់ | ១៥ នាទី |
| ០៩:០០ - ០៩:០៥ | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និងគោរពវិញ្ញាណក្ខន្ធវីរៈកងទ័ព និងវីរៈនគរបាលជាតិ | ៥ នាទី |
| ០៩:០៥ - ០៩:២០ | សុន្ទរកថាស្វាគមន៍ ដោយ**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុខ ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ជាប្រធាន **គ.ផ.គ.ព.** និងជាអនុប្រធាន **គ.ក.ច.** | ១៥ នាទី |
| ០៩:២០ - ០៩:៤០ | សុន្ទរកថាបើកកម្មវិធី ដោយ**ឯកឧត្តម ខេង ជីវិសុទ្ធ** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ក.ច.** | ២០ នាទី |
| ០៩:៤០ - ១០:១០ | **<u>បទបង្ហាញស្ដីពី៖</u> ទស្សនាទានស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា**<br>- **ឯកឧត្តម លី ច័ន្ទតុលា** រដ្ឋលេខាធិការ អនុប្រធាន និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** | ៣០ នាទី |
| ១០:១០ - ១១:១០ | **<u>បទបង្ហាញស្ដីពី៖</u> វិធីសាស្ត្រនៃការធ្វើក្រមពាណិជ្ជកម្មនិងវិសាលភាពនៃទំនាក់ទំនងពាណិជ្ជកម្មនៅប្រទេសបារាំង**<br>- **Mrs. ELISABETH CATTA**, Honorary Advocate General, Paris Court of Appeal, and a former member of the High Commission for Codification.<br>- **Dr. ANNE-SOPHIE LAFFITTE-MILARD**, Lecturer in Law, Université Paris 1 Panthéon-Sorbonne, Researcher, Institut de Recherche Juridique de la Sorbonne, and Ph.D. in Comparative Law. | ៦០ នាទី |
| ១០:១០ - ១១:៣០ | សម្រាកពិសាអាហារសម្រន់ | ២០នាទី |
| ១១:៣០ - ១២:៣០ | **<u>វេទិកាសំណួរ-ចម្លើយ៖</u> ទស្សនាទានស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា វិធីសាស្ត្រនៃការធ្វើក្រមពាណិជ្ជកម្មនិងវិសាលភាពនៃទំនាក់ទំនងពាណិជ្ជកម្មនៅប្រទេសបារាំង**<br>- **ឯកឧត្តម លី ច័ន្ទតុលា** រដ្ឋលេខាធិការអនុប្រធាននិងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.**<br>- **Mrs. Elisabeth CATTA**, Honorary Advocate General, Paris Court of Appeal, and a former member of the High Commission for Codification. | ៦០ នាទី |

| ម៉ោង | កម្មវិធី | រយៈពេល |
|---|---|---|
| | - **Dr. ANNE-SOPHIE LAFFITTE-MILARD**, Lecturer in Law, Université Paris 1 Panthéon-Sorbonne, Researcher, Institut de Recherche Juridique de la Sorbonne, and Ph.D. in Comparative Law. | |
| ១២:៣០- ១៤:៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ | ១២០ នាទី |
| ១៤:៣០ - ១៦:១០ | វេទិកាពិភាក្សាអំពី៖ **វិធីសាស្ត្រតាក់តែងក្រម និងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា**<br>វាគ្មិន ៧ រូប ត្រូវបានអញ្ជើញឡើងលើវេទិកា៖<br>- **ឯកឧត្តមបណ្ឌិត ហ៊ើល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិក **គ.ក.ច.** (អ្នកសម្របសម្រួល)<br>- **ឯកឧត្តម ប៊ួន សារៈមុនី** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម<br>- **ឯកឧត្តម កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌<br>- **ឯកឧត្តម តាន់ហ៊ាង ជាវ័ណ្ណ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌<br>- **ឯកឧត្តម ស៊ុម សុខម្ភ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន<br>- **Mrs. Elisabeth CATTA**, Honorary Advocate General, Paris Court of Appeal, and a former member of the High Commission for Codification.<br>- **Mr. SAKANO ISSEI**, Advisor to the Ministry of Justice of Cambodia. | ១០០នាទី |
| ១៦:១០ - ១៦:៣០ | សម្រាកពិសារអាហារសម្រន់ | ២០នាទី |
| ១៦:៣០ - ១៧:៣០ | វេទិកាពិភាក្សាលើប្រធានបទ៖ វិសាលភាពនៃវិធានពាណិជ្ជកម្មដែលត្រូវបញ្ចូលក្នុងក្រមពាណិជ្ជកម្មកម្ពុជា<br>វាគ្មិន ៨រូប ត្រូវបានអញ្ជើញឡើងលើវេទិកា៖<br>- **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ជាប្រធាន **គ.ផ.គ.ព.** និងជាអនុប្រធាន **គ.ក.ច.** (អ្នកសម្របសម្រួល)<br>- **ឯកឧត្តម ជីវ សុខហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធាន គ.ក.ប.<br>- **លោកជំទាវ តាន់ ទេពីកណ្ណិកា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម<br>- **ឯកឧត្តម តាំង ស៊ុនឡាយ** អនុប្រធានតុលាការកំពូល<br>- **Dr. ANNE-SOPHIE LAFFITTE-MILARD**, Lecturer in Law, Université Paris 1 Panthéon-Sorbonne, Researcher, Institut de Recherche Juridique de la Sorbonne, and Ph.D. in Comparative Law. | ៦០ នាទី |

| ម៉ោង | កម្មវិធី | រយៈពេល |
|---|---|---|
| | - **Mr. KAZUAKI TAKAHASHI**, UNCITRAL, Regional for Asia and the Pacific.<br>- **លោក លី តៃសេង** នាយកប្រតិបត្តិ នៃក្រុមហ៊ុនមេធាវី HBS Law<br>- **ឧកញ៉ា បណ្ឌិត តាន់ មុនីវណ្ណ** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា សហប្រធានក្រុមការងារ "ទី១៣/ឌ" ផ្នែកសំណង់និងអចលនទ្រព្យ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (វ.រ.ឯ) | |
| ១៧:៣០ | **សុន្ទរកថាបិទកម្មវិធី** ដោយ **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ក.ច.** | - |

**** គ.ក.ច. រក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។*

ក្រុមតេឡេក្រាម
សម្រាប់សិក្ខាសាលាស្តីពីការរៀបចំក្រុមពាណិជ្ជកម្មសម្រាប់កម្ពុជា

ឯកសារពាក់ព័ន្ធនឹង
សិក្ខាសាលាស្តីពីការរៀបចំក្រុមពាណិជ្ជកម្មសម្រាប់កម្ពុជា

# គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

អាសយដ្ឋាន៖ ទីស្ដីការគណៈរដ្ឋមន្ត្រីអាគារមិត្តភាព, ៤១ មហាវិថី សហព័ន្ធរុស្សី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

សារអេឡិចត្រូនិក៖ info@lrc.gov.kh គេហទំព័រ៖ www.lrc.gov.kh

លេខទូរស័ព្ទ៖ +855 11 625 351